00961011

E301

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 11 / 2013
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SAMN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**ផ្ញើជូន៖** គ្រប់ភាគីទាំងអស់ ក្នុងសំណុំរឿង ០០២

**ពី៖** ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រី ចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២

១) នៅក្នុង "សេចក្តីសម្រេចរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការនៃសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣" (E284) អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីចេតនាក្នុងការរៀបចំកិច្ចប្រជុំរៀបចំសវនាការនា នាចុងឆ្នាំនេះ ដើម្បីស្តាប់មតិយោបល់របស់ភាគីស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២។

២) ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជូនដំណឹងដល់គ្រប់ភាគីទាំងអស់ឲ្យបានជ្រាបថា អង្គជំនុំជម្រះនឹងរៀបចំកិច្ចប្រជុំរៀបចំសវនាការមួយសម្រាប់សំណុំរឿង ០០២/០២ នៅថ្ងៃទី ១១ និងទី១២ ខែ ធ្នូ ឆ្នាំ ២០១៣ នេះ។ ប្រសិនបើកិច្ចប្រជុំរៀបចំសវនាការនេះមិនអាចបញ្ចប់នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ តាមការគ្រោងទុកទេនោះ កិច្ចប្រជុំនេះនឹងបន្តធ្វើនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៣ ទៀត។ បែបបទនៃកិច្ចប្រជុំនេះនឹងយកតាមលំនាំនៃទម្រង់កិច្ចប្រជុំរៀបចំសវនាការកាលពីលើកមុនៗក្នុង សំណុំរឿង ០០២/០១។

៣) គោលបំណងនៃកិច្ចប្រជុំរៀបចំសវនាការនេះ គឺដើម្បីសម្រួលដល់ការរៀបចំផែនការសម្រាប់សំណុំរឿង ០០២/០២។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងមានបំណងចង់លើកបញ្ហាមួយចំនួនដូច ខាងក្រោម សម្រាប់ពិភាក្សាជាមួយភាគី ដែលបញ្ហាទាំងនោះរួមមាន៖

ក) **វិសាលភាពនៃសំណុំរឿង ០០២/០២ (និងផ្នែកពាក់ព័ន្ធដែលជាកម្មវត្ថុនៃការជំនុំជម្រះនៅពេលអនាគត)** ៖ អង្គជំនុំជម្រះសាលាដំបូងនឹងស្នើឱ្យភាគីដាក់សំណើពាក់ព័ន្ធនឹងបទចោទនានា ដែលត្រូវយកមកជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ ជាពិសេស អង្គជំនុំជម្រះសូមស្នើភាគីឱ្យចាប់អារម្មណ៍ទៅលើ "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលា-ដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២" (ឯកសារ E284/4/7) និង "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១" (ឯកសារ E163/ 5/1/13)។ ភាគីអាចលើកជាមតិយោបល់ពាក់ព័ន្ធនឹងទម្រង់នៃសំណុំរឿង ០០២/០២ ដែលបានស្នើឡើងនៅក្នុងសេចក្តីសម្រេចទាំងពីរនេះ ដោយពិចារណាទៅលើលក្ខខណ្ឌតម្រូវឱ្យមានភាពយុត្តិធម៌ និងឆាប់រហ័ស សិទ្ធិរបស់ជនជាប់-ចោទ និងលក្ខណៈវិនិច្ឆ័យលើ "ភាពតំណាងសមស្រប" ដូចអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងក្នុងឯកសារ E163/5/1/13។ ភាគីអាចលើកឡើងដោយសង្ខេប និងដោយគោលៗប៉ុណ្ណោះនៅចំពោះមុខអង្គជំនុំជម្រះ អំពីទំនាក់ទំនងរវាងសំណុំរឿង ០០២/០២ និងដំណាក់កាលជំនុំជម្រះក្តីផ្សេងទៀតនាពេលអនាគតក្នុងសំណុំរឿង ០០២ ប្រសិនបើមាន។

ខ) **កាលបរិច្ឆេទបណ្តោះអាសន្នសម្រាប់សវនាការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២**៖ ទោះបីថានៅដំណាក់កាលនេះ ជាដំណាក់កាលដំបូងនៃការពិភាក្សាអំពីការត្រៀមរៀបចំសម្រាប់ការជំនុំជម្រះសំណុំរឿង ០០២/០២ ដែលវិសាលភាពជាក់លាក់នៃសំណុំរឿងនេះនឹងត្រូវកំណត់ដោយអង្គជំនុំជម្រះនាពេលអនាគតក៏ដោយ ក៏អង្គជំនុំជម្រះស្នើសុំឱ្យភាគីដាក់សំណើពាក់ព័ន្ធនឹងកាលបរិច្ឆេទកំណត់ថ្ងៃសវនាការ (និងកិច្ចប្រជុំរៀបចំសវនាការនាពេលអនាគត) ក្នុងសំណុំរឿង ០០២/០២ ផងដែរ។ ភាគីត្រូវត្រៀមខ្លួនដើម្បីផ្តល់ការប៉ាន់

E301

ប្រមាណជាបឋម អំពីលទ្ធភាពចូលរួមរបស់ខ្លួន និងពេលវេលាត្រៀមរៀបចំដែលនឹងត្រូវត្រូវការ។ អង្គជំនុំជម្រះនឹងផ្តល់ការប៉ាន់ស្មានបណ្តោះអាសន្នរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះផងដែរ។

៤) អង្គជំនុំជម្រះស្នើភាគីឱ្យផ្តល់យោបល់ចំពោះរបៀបវារៈដែលបានស្នើឡើងខាងលើ។ ជាពិសេស សូមភាគីបញ្ជាក់ថាតើមានបញ្ហាអ្វីផ្សេងទៀត ដែលខ្លួនយល់ថាគួរលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការខាងមុខនេះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា កិច្ចប្រជុំរៀបចំសវនាការបន្ថែមទៀតសម្រាប់សំណុំរឿង ០០២/០២ នឹងត្រូវរៀបចំឡើងនាពេលខាងមុខដើម្បីដោះស្រាយបញ្ហាជាក់ស្តែង បញ្ហានីតិវិធី និងបញ្ហាបច្ចេកទេស នៅពេលដែលវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានកំណត់ឱ្យបានច្បាស់លាស់ជាងនេះរួចសិន។

៥) អង្គជំនុំជម្រះស្នើដល់ភាគីផ្ញើនូវមតិយោបល់មកអង្គជំនុំជម្រះតាមរយៈអ៊ីម៉េលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ និងសូមចម្លងជូនភាគីផ្សេងៗទៀតនៃរឿងក្តីផងដែរ។ បន្ទាប់ពីអង្គជំនុំជម្រះបានទទួល និងពិចារណាលើសំណើរបស់ភាគីរួចហើយ អង្គជំនុំជម្រះនឹងចេញរបៀបវារៈចុងក្រោយមួយសម្រាប់កិច្ចប្រជុំរៀបចំសវនាការ ដោយនៅក្នុងរបៀបវារៈនេះនឹងមានកំណត់បញ្ហាជាក់លាក់មួយចំនួនដែលភាគីត្រូវពិភាក្សាដោះ ស្រាយនៅក្នុងកិច្ចប្រជុំ។ របៀបវារៈចុងក្រោយនេះនឹងត្រូវដាក់ ព្រមទាំងចែកជូននៅមុនកិច្ចប្រជុំ ដើម្បីទុកឱ្យភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមរៀបចំសំណើ ឬមតិយោបល់របស់ខ្លួន។